# តើអ្នកដឹងទេ?
## អំពី ប្រាក់បៀវត្សអប្បបរមា

### ខេត្តអៃឈិ ប្រាក់បៀវត្សអប្បបរមា

**986** យ៉េន (ចំនួនទឹកប្រាក់ក្នុងមួយម៉ោង)

ចាប់ពីថ្ងៃទី1 ខែតុលា ឆ្នាំ2022 នេះតទៅ

ធៀបនឹងឆ្នាំមុន **31** យ៉េន UP

វាជាវិធានសម្រាប់អ្នកធ្វើការគ្រប់គ្នាដូចជាបុគ្គលិកក្រុមហ៊ុនពេញសិទ្ធិ អ្នកធ្វើការងារក្រៅម៉ោង អ្នកធ្វើការតាមកិច្ចសន្យា និងសិស្សនិស្សិតជាដើម និងសម្រាប់អ្នកជួលបុគ្គលិកឲ្យធ្វើការងារ!



カンボジア語版

ប្រាក់បៀវត្សអប្បបរមា គឺជាប្រព័ន្ធដែលធានា និងការពារនូវចំនួនទឹកប្រាក់អប្បបរមានៃប្រាក់បៀវត្សសម្រាប់បុគ្គលិកគ្រប់គ្នា។

ឆែកតាម WEB!!

វេបសាយពិសេសដែលទាក់ទងនឹងប្រាក់បៀវត្សអប្បបរមា(មានតែភាសាជប៉ុន): https://www.saiteichingin.info/

最低賃金制度 検索

ពាក់ព័ន្ធនឹងប្រាក់បៀវត្សអប្បបរមា សូមទាក់ទងមកនាយកដ្ឋានការងារខេត្តអៃឈិ ឬការិយាល័យត្រួតត្រាស្តង់ដារការងារនៅជិតលោកអ្នកបំផុត។

អាសយដ្ឋានវេបសាយរបស់នាយកដ្ឋានការងារខេត្តអៃឈិ: https://jsite.mhlw.go.jp/aichi-roudoukyoku/

ចំពោះលោក លោកស្រីដែលជាម្ចាស់ក្រុមហ៊ុនរកស៊ីខ្នាតតូច និងមធ្យម

業務改善助成金

ជួយឧបត្ថម្ភយ៉ាងច្រើនបំផុតត្រឹម 600 ម៉ឺនយ៉េន

ក្រសួងសុខាភិបាល ការងារ និងសុខុមាលភាព

# "ប្រព័ន្ធប្រាក់បៀវត្សអប្បបរមា"

## គឺជាប្រព័ន្ធដែលធានា និងការពារនូវចំនួនទឹកប្រាក់អប្បបរមានៃប្រាក់បៀវត្ស (ចំនួនទឹកប្រាក់បៀវត្សអប្បបរមា) សម្រាប់បុគ្គលិកគ្រប់គ្នាណា!

ត្រូវអនុវត្តចំពោះបុគ្គលិកទាំងអស់ ទោះបីជាមានអាយុ ឬរបៀបធ្វើការខុសគ្នា ដូចជាការងារមិនពេញម៉ោង ឬការងារក្រៅម៉ោងរបស់សិស្សនិស្សិតជាដើមក៏ដោយ។



## របៀបឆែកមើលដូចម្ដេច?

សូមគណនាចំនួនទឹកប្រាក់ក្នុងមួយម៉ោងរបស់ប្រាក់បៀវត្សដែលចង់ឆែក (*1) រួចយកវាមកប្រៀបធៀបជាមួយចំនួនទឹកប្រាក់បៀវត្សអប្បបរមា (ចំនួនទឹកប្រាក់ក្នុងមួយម៉ោង)!

### វិធីប្រៀបធៀបជាមួយចំនួនទឹកប្រាក់បៀវត្សអប្បបរមា

សូមសរសេរចូលនូវចំនួនទឹកប្រាក់បៀវត្សរបស់អ្នក និងចំនួនទឹកប្រាក់បៀវត្សអប្បបរមានៅទីក្រុង ឬខេត្តដែលត្រឹមត្រូវ។(*2)

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| **1** ក្នុងករណីប្រាក់ខែតាមម៉ោង | ប្រាក់ខែតាមម៉ោង ____ យ៉េន | ≥ | ចំនួនទឹកប្រាក់បៀវត្សអប្បបរមា (ចំនួនទឹកប្រាក់ក្នុងមួយម៉ោង) ____ យ៉េន | | | | | |
| **2** ក្នុងករណីប្រាក់ខែតាមថ្ងៃ | ប្រាក់ខែតាមថ្ងៃ ____ យ៉េន | ÷ | ចំនួនមធ្យមនៃម៉ោងធ្វើការក្នុងមួយថ្ងៃដែលកំណត់ ____ ម៉ោង | = | ចំនួនទឹកប្រាក់ក្នុងមួយម៉ោង ____ យ៉េន | ≥ | ចំនួនទឹកប្រាក់បៀវត្សអប្បបរមា (ចំនួនទឹកប្រាក់ក្នុងមួយម៉ោង) ____ យ៉េន | |
| **3** ក្នុងករណីប្រាក់ខែតាមខែ | ប្រាក់ខែតាមខែ ____ យ៉េន | ÷ | ចំនួនមធ្យមនៃម៉ោងធ្វើការក្នុង១ខែដែលកំណត់ ____ ម៉ោង | = | ចំនួនទឹកប្រាក់ក្នុងមួយម៉ោង ____ យ៉េន | ≥ | ចំនួនទឹកប្រាក់បៀវត្សអប្បបរមា (ចំនួនទឹកប្រាក់ក្នុងមួយម៉ោង) ____ យ៉េន | |

**4** ក្នុងករណីដែលរួមបញ្ចូលគ្នាចំណុច 1 2 និង 3 ខាងលើនេះ

ឧទាហរណ៍ ក្នុងករណីដែលប្រាក់ខែគោល គឺប្រាក់ខែតាមថ្ងៃ ប៉ុន្តែប្រាក់បន្ថែមផ្សេងៗ (ដូចជាប្រាក់បន្ថែមលើភារកិច្ច) ត្រូវបានបើកជូនជាប្រចាំខែ

❶ ប្រាក់ខែគោល (ប្រាក់ខែតាមថ្ងៃ) → គណនាចំនួនទឹកប្រាក់ក្នុងមួយម៉ោង តាមការគណនា 2
❷ ប្រាក់បន្ថែមផ្សេងៗ (ប្រាក់ខែតាមខែ) → គណនាចំនួនទឹកប្រាក់ក្នុងមួយម៉ោង តាមការគណនា 3
❸ ចំនួនទឹកប្រាក់សរុបដែលបូក ❶ និង ❷ ≥ ចំនួនទឹកប្រាក់បៀវត្សអប្បបរមា (ចំនួនទឹកប្រាក់ក្នុងមួយម៉ោង)

(*1) ក្នុងការប្រៀបធៀបជាមួយចំនួនទឹកប្រាក់បៀវត្សអប្បបរមា មិនគិតរួមនូវប្រាក់បៀវត្សដូចតទៅ៖ ① ប្រាក់បៀវត្សដែលទូទាត់បណ្ដោះអាសន្ន (ដូចជាប្រាក់ឧបត្ថម្ភសម្រាប់ការរៀបអាពាហ៍ពិពាហ៍) ② ប្រាក់បៀវត្សដែលទូទាត់រាល់រយៈពេលដែលលើសពី១ខែ (ដូចជាប្រាក់រង្វាន់លើកទឹកចិត្ត) ③ ប្រាក់បៀវត្សដែលទូទាត់សម្រាប់ម៉ោងធ្វើការដែលហួសពីម៉ោងការងារដែលកំណត់ (ដូចជាប្រាក់បៀវត្សបន្ថែមទៅលើការងារថែមម៉ោង) ④ ប្រាក់បៀវត្សដែលទូទាត់សម្រាប់ម៉ោងធ្វើការក្នុងថ្ងៃដែលមិនមែនជាថ្ងៃការងារដែលកំណត់ (ដូចជាប្រាក់បៀវត្សបន្ថែមលើការងារនៅថ្ងៃឈប់សម្រាក) ⑤ ចំនួនលើសពីចំនួនទឹកប្រាក់ដែលគណនាប្រាក់បៀវត្សតាមម៉ោងការងារធម្មតា ក្នុងប្រាក់បៀវត្សដែលទូទាត់ចំពោះការងារក្នុងរយៈពេលចាប់ពីម៉ោង១០យប់ រហូតដល់ម៉ោង៥ព្រឹក។ (ប្រាក់បៀវត្សបន្ថែមលើការងារពេលយប់) ⑥ ប្រាក់បន្ថែមសម្រាប់ការវត្តមានមិនឈប់សោះ ប្រាក់បន្ថែមសម្រាប់ការធ្វើដំណើរ និងប្រាក់ឧបត្ថម្ភសម្រាប់គ្រួសារ

(*2) វិធីគណនាលម្អិត និងវិធីគណនាក្នុងករណីប្រាក់ខែតាមលទ្ធផលស្នាដៃ សូមទាក់ទងមកការិយាល័យត្រួតត្រាស្តង់ដារការងារឬនាយកដ្ឋានការងារនៅជិតលោកអ្នកបំផុត

## ទាំងនិយោជក និងនិយោជិត ត្រូវពិនិត្យមើលប្រាក់បៀវត្សអប្បបរមាកុំខាន។

តោះ ឆែកប្រាក់បៀវត្សអប្បបរមាក្នុងតំបន់ខ្លួនឯង នៅលើទូរសព្ទដៃ និងស្មាតហ្វូន! (មានតែភាសាជប៉ុន)

# 業務改善助成金

ជួយឧបត្ថម្ភយ៉ាងច្រើនបំផុតត្រឹម 600 ម៉ឺនយ៉េន

"ប្រាក់ឧបត្ថម្ភលើកកម្ពស់ផ្នែកធុរកិច្ច"គឺជាប្រាក់ឧបត្ថម្ភដែលផ្ដល់ជំនួយដល់សហគ្រាសតូចនិងមធ្យម និងប្រតិបត្តិករអាជីវកម្មខ្នាតតូច ដែលមានគោលដៅបង្កើនផលិតភាព និងដំឡើង "ប្រាក់បៀវត្សទាបបំផុតនៅក្នុងកន្លែងធ្វើអាជីវកម្ម(ប្រាក់បៀវត្សអប្បបរមាក្នុងកន្លែងធ្វើអាជីវកម្ម)" ។ ក្នុងករណីដែលបានធ្វើការវិនិយោគលើសម្ភារៈជាដើម យើងនឹងឧបត្ថម្ភមួយផ្នែកនៃចំណាយនោះអាស្រ័យតាមលក្ខខណ្ឌចាំបាច់ត្រូវផ្ដល់ឲ្យ។



**ចំពោះលោក លោកស្រីដែលជាម្ចាស់ក្រុមហ៊ុនរកស៊ីខ្នាតតូច និងមធ្យម**

តោះ នាំគ្នាប្រើប្រាស់ឲ្យសកម្មនូវប្រាក់ឧបត្ថម្ភដែលគាំទ្រការដំឡើងប្រាក់បៀវត្ស។

មានវីដេអូអំពីប្រាក់ឧបត្ថម្ភលើកកម្ពស់ផ្នែកធុរកិច្ចផងដែរ។

ព័ត៌មានលម្អិតសូមឆែកមើលនៅទីនេះ៖ (មានតែភាសាជប៉ុន) [業務改善助成金] [検 索]

### លក្ខខណ្ឌចាំបាច់ត្រូវផ្ដល់ឲ្យ

1. ដំឡើងប្រាក់បៀវត្សអប្បបរមាក្នុងកន្លែងធ្វើអាជីវកម្ម
2. ទូទាត់ប្រាក់បៀវត្សក្រោយដំឡើង
3. ដាក់បញ្ចូលម៉ាស៊ីនឧបករណ៍និងសម្ភារៈជាដើមដើម្បីបង្កើនផលិតភាព
4. គ្មានមូលហេតុនៃការមិនផ្ដល់ការឧបត្ថម្ភដូចជាការបញ្ឈប់ពីការងារ ការបញ្ចុះប្រាក់បៀវត្សជាដើម

▶ ឧបត្ថម្ភមួយផ្នែកនៃចំណាយចាំបាច់សម្រាប់ការវិនិយោគលើសម្ភារៈជាដើម

### ជំហានរហូតដល់ការផ្ដល់ប្រាក់ឧបត្ថម្ភ

1. ដាក់ពាក្យស្នើសុំប្រាក់ឧបត្ថម្ភនិងផែនការអនុវត្តគម្រោងជាដើមទៅនាយកដ្ឋានការងារនៃទីក្រុងឬខេត្តដែលនៅជិតបំផុត
▶ ត្រួតពិនិត្យ
2. ក្រោយសម្រេចផ្ដល់ប្រាក់ឧបត្ថម្ភ អនុវត្តគម្រោងតាមផែនការដែលបានដាក់ពាក្យមក
▶
3. រាយការណ៍លទ្ធផលអនុវត្តគម្រោងទៅកាន់នាយកដ្ឋានការងារ
▶ ត្រួតពិនិត្យ
4. ផ្ដល់ឲ្យ

### ផ្ដល់ការពិភាក្សាដោយឥតគិតថ្លៃជាមួយអ្នកជំនាញ

អ្នកដែលមានកង្វល់អំពីការដំឡើងប្រាក់បៀវត្ស សូមពិភាក្សាជាមួយមជ្ឈមណ្ឌលគាំទ្រលើកកម្ពស់កំណែទម្រង់របៀបធ្វើការ។

ព័ត៌មានលម្អិតសូមឆែកមើលនៅទីនេះ៖ (មានតែភាសាជប៉ុន) [働き方改革推進支援センター] [検 索]

### មូលនិធិគាំទ្រកំណែទម្រង់របៀបការងារ

សាជីវកម្មហិរញ្ញវត្ថុនយោបាយជប៉ុន កំពុងធ្វើការផ្ដល់ឥណទានលើប្រាក់សម្ភារៈ និងប្រាក់គ្រប់គ្រងចំពោះអ្នកព្យាយាមដំឡើងប្រាក់បៀវត្សអប្បបរមានៅក្នុង កន្លែងធ្វើអាជីវកម្ម។

ព័ត៌មានលម្អិតសូមឆែកមើលនៅទីនេះ៖ (មានតែភាសាជប៉ុន) [働き方改革推進支援資金] [検 索]

リサイクル適性Ⓐ
この印刷物は、印刷用の紙へリサイクルできます。

(R4.9)